នារីសម្លឹងទៅស្រោមសំបុត្រនោះ តែនៅមិនហ៊ានទទួលយកនៅឡើយ។ វាដូចណាស់ទៅនឹងសំណុំរូបថតក្នុងវីដេអូមុននេះ។ នាងពិតជាចង់ដឹងណាស់ថា ជារូបអ្វី? ហេតុអ្វីប្ដីនាងមុនស្លាប់សោយសោកម្នាក់ឯងលាក់កំបាំងពីនាង។

ទោះនារីមិនទទួលយក តែបុរសបានញញឹមជូរចត់ លូកចេញមកបង្ហាញនាងម្ដងមួយសន្លឹកៗ។

បេះដូងហាន់ដា ត្រូវវារាំងចង្វាក់នីមួយៗដោយភាពស្រងាកចិត្ត។

វាជារូបភាពកៀកស្និទ្ធពីរបីសន្លឹករវាងនាងនិងសុងសក្តិ តាំងពីពេលណាមកមិនដឹង តែនាងច្បាស់ប្រាកដថានាងមិនមានទំនាក់ទំនងអ្វីដូចដែលរូបថតនេះកំពុងប្រាប់ទេ។

ត្រូវហើយ!

នាងនឹកឃើញភ្លាម អំពីសិក្ខាសាលាមួយដែលនាងនឹងគេបានសម្ដែងល្ខោនជាមួយគ្នាក្នុងមន្ទីរពេទ្យជាផ្នែកមួយនៃការសិក្សាអំពីមធ្យោបាយសង្គ្រោះផ្លូវចិត្តហើយក្រុមសិក្ខាកាមនីមួយៗត្រូវបានតម្រូវអោយបង្កើតជាឆាកល្ខោននិយាយអំពី ការគាំទ្ររបស់ក្រុមគ្រួសារចំពោះអ្នកមានជំងឺផ្នែកស្មារតី។

នាងងើបមុខសម្លឹងគីម៉ាល់ ហើយនិយាយទាំងខូចចិត្តៈ

«ពិសិដ្ឋគួរតែសួរខ្ញុំមួយម៉ាត់ ហេតុអី? ហេតុអីគេខឹងមិននិយាយ? គេគួរតែទុកពេលឱ្យខ្ញុំពន្យល់ប្រាប់!»

បងថ្លៃម្នាក់នេះក្ដាប់មាត់ហាក់គ្នាន់ក្នាញ់នឹងឫកពាសម្ដែងធ្វើជាមនុស្សមិនមានកំហុសសមឥតទាស់របស់នាង។

«ជឿមិនជឿក៏ដោយ នេះជាការសម្ដែងពេលរៀនរួមគ្នា! អ្នកណាគំនិតអាក្រក់ម្ល៉េះ? យករូបរបៀបនេះទៅបង្ហាញសិដ្ឋឱ្យយល់ខុស! គេធ្វើអីខ្លះពីក្រោយខ្នងខ្ញុំពេលខ្ញុំមិននៅ  បានជាសិដ្ឋក្លាយជាអ៊ីចឹង ធម្មតាគេជាមនុស្សចិត្តទូលាយយល់ហេតុនិងផលណាស់!»

«ប្អូនខ្ញុំចិត្តទូលាយណាស់ហាន់ដា ដល់ថ្នាក់ត្រូវគេបោកប្រាស់ពេញមួយជីវិត ដល់ថ្ងៃស្លាប់ទៅ នៅតែមានៈការពារគេ គិតគូគេ!»

បុរសនិយាយឌឺដងធ្វើឱ្យនាងកាន់តែរងវិបត្តិ។

«ខ្ញុំមិនបានធ្វើអីខុសចំពោះគាត់ ខ្ញុំមិនខ្វល់អ្នកណាគិតថាម៉េចទេ? បាបកម្មរបស់អ្នកដែលប្រឹងប្រតិដ្ឋរឿងទៅបំភាន់គាត់ អ្នកនោះនឹងទទួលដោយខ្លួនគេ! ហើយបើមានគេណាម្នាក់ មិនសប្បាយចិត្តរឿង

កេរមរតកដែលគាត់ទុកមកឱ្យខ្ញុំហ្នឹងក៏ យកចុះ! យកចុះណ៎ា យកទាំងអស់ចុះ ហើយកុំរវល់នឹងជីវិតខ្ញុំ!»

«នឹងអាលបានទំនេរ ទៅរកអាពួកប្រុសស្អាតៗដែលនៅបន្តជាជួររង់ចាំឱ្យរហង់នោះអី?»

សម្ដីគេធ្វើឱ្យនាងនឹកឃើញភ្លាមដល់ហេតុផលដែលត្រូវបានបង្ខំមកដល់ទីនេះ ។ ម៉ោងនេះពេលនេះ នាងនឹកឃើញឡើងវិញដល់និវត្ត។ លែងរវល់តបតអ្វីទៀតហើយ ព្រោះដឹងចរិតរបស់គេដែលកម្រោលខ្មោចចេញ ខ្មោចចូលមិនទៀងទាត់។

«គិតម៉េចគិតទៅ ខ្ញុំអត់មានសិទ្ធិអីទៅហាមគំនិតអ្នកណាទេ!»

នាងថាហើយច្រត់ដៃក្រោក។

«អង្គុយចុះ!»

គេបញ្ជាខ្លីៗ ជាមួយសំឡេងស្រាលៗ។ ទោះយ៉ាងណា នាងដឹងថា នេះជាចរិតគេ តែនាងតាំងចិត្តហើយថា មិនស្ដាប់មិនព្រមចាញ់សម្លុត។

«ទុកឱ្យគ្រប់គ្នាបានសុខផងគីម៉ាល់ ឱ្យគេនាំប្អូនខ្ញុំមកវិញឥឡូវនេះ!»

«ប្រាប់ឱ្យអង្គុយចុះវិញ!»

បុរសផ្ទួនសម្ដីធ្វើឱ្យដង្ហើមខាងស្រីទៅជាញាប់មិនស្រួលចិត្តទេ។ នាងសម្លឹងគេដែលនៅអង្គុយចំពោះមុខ។ កែវភ្នែកគីម៉ាល់ទាំងសងខាង បញ្ចេញភាពទោមនស្ស ខុសពីវិនាទីទាំងប៉ុន្មានមុននេះ។ នាងមិនដឹងថា ពាក្យចុងក្រោយណាមួយដែលនាំឱ្យគេកើតទោសៈឡើងបានភ្លាមៗបែបនេះនោះទេ តែកម្រិតនៃកំហឹងដ៏សាហាវរបស់គេ នាងមានបទពិសោធន៍រួចហើយកាលពីនៅលើទូក។

ពីចំហៀងខាងឆ្វេងនាងឃើញស្រមោលទូកតូចវិលមកវិញ។

គេមិនបានធ្វើអ្វីប្អូននាងទេ ប្រហែលជាការនាំនិវត្តមកទីនេះក៏ដើម្បីបង្ខំនាងឱ្យមកជួបគេ នឹងអាលបានបកស្រាយរឿងអស់ទាំងនេះ។ តែនាងយល់ថា លែងមានអ្វីត្រូវបកស្រាយហើយ។ មនុស្សដែលនាងគួរមានឱកាសបកស្រាយប្រាប់ បានស្លាប់លែងមានពេលឮទៅហើយ និយាយបានប្រយោជន៍អី? គេនេះត្រូវជាអ្វីនឹងនាង? ចាំបាច់អីចំណាយពេលពន្យល់គេ ចង់គេគិតថានាងល្អ ឬមិនល្អ វាជាឯកសិទ្ធិរបស់គេតាមចិត្តទៅចុះ។

«ខ្ញុំអស់អីត្រូវនិយាយហើយ! ហើយក៏គ្មានអីដែលខ្ញុំចង់យកតាមទៀតដែរ គីម៉ាល់! អាចដំណើរការរឿងមរតកហ្នឹងពេលណាក៏បាន ស្អែកនេះក៏បាន កាន់តែឆាប់កាន់តែល្អ! ហើយយើងឈប់ពាក់ព័ន្ធគ្នា!»

«ចុះលុយ៧០ម៉ឺនទៀត?!»

ប្អូននាងឡើងមកដល់ច្រាំងទាំងញញឹមញញែមជាមួយនឹងម៉ាស៊ីនថតក្នុងដៃ តាមថានាងអាចរត់ទៅរកគេ តែពាក្យចុងក្រោយធ្វើឱ្យនាងទ្រឹង។

ត្រូវហើយនាងភ្លេចឱ្យឈឹងអំពីបំណុលដែនកោះរាប់សិបម៉ឺនដុល្លារនៅពីក្រោយហេតុផលដែលនាងសម្រេចចិត្តរៀបការជាមួយពិសិដ្ឋ។

នាងបែរមុខទៅរកកូនទូកនឹងច្រាំងទន្លេ ប៉ុន្តែគ្រប់យ៉ាងត្រូវបិទបាំងដោយសារម្ចាស់បន្ទប់ក្រោកមកហើយទាញវាំងននបិទខ្ទាក។

បុរសនេះទាញបង្វែរនាងឱ្យវិលមកប្រឈមនឹងខ្លួន។

«លុយ៧០ម៉ឺនដុល្លារស្មានថារឿងតូចតាចប្អូនថ្លៃសំណព្វ?»

នាងគាំងទៀតហើយ ដោយសម្លឹងគេភ្លឹះៗតាមរបៀបមនុស្សពិរុទ្ធគ្មានសិទ្ធិហាស្តី។

«មរតកមិនយកក៏មិនទាន់រួចខ្លួនដែរ លើកលែងតែយកលុយមកសងវិញគ្រប់ចំនួនផង ប្អូនថ្លៃជើងល្អ!»

«ខ្ញុំគ្មានទេគីម៉ាល់!»

នាងហាចេញដោយឯកឯង ដោយអស់ពីជម្រៅចិត្ត ដោយគ្មានអ្វីត្រូវលាក់កំបាំងនិងគ្មានហេតុផលណាមួយអាចយកមកជាលេសគេចវេះបានទាំងអស់។

បុរសនេះញញឹមចំអកកែវភ្នែកព្រួយបារម្ភរបស់នាង។ គេនិយាយទាំងជូរចត់៖

«ក្រែងកុងត្រារៀបការ ធ្វើប្រពន្ធមួយជីវិតតម្លៃ៧០ម៉ឺនដុល្លារ ចុះបើបញ្ឈើប្តីឱ្យស្លាប់មុនកាលកំណត់ទាំងដើមទាំងការ គិតទូទាត់របៀបម៉េច? អ្ហះ? អ្នកវិនិយោគទុនសេវាកម្មផ្សំដំណេក? បានអ្នកណាទទួលយកសេវាកម្មបន្តទៅបើម្ចាស់បំណុលត្រូវស្លាប់កណ្តាលទីទៅហើយ?»

នារីលើកដៃទាំងទ្វេច្រានបុរសនេះចេញពីមុខនាងដោយកំហឹង។

សម្តីមាក់ងាយចុងក្រោយរបស់គេធ្វើឱ្យចិត្តនាងសឹងរលត់សូន្យដូចចង្កៀងអស់ប្រេង។

«គ្មានកុងត្រាឆ្កួតយកអីលោកឯងទេ!»

នាងខឹងណាស់ នេះជាសម្ដីកាចបំផុតដែលនាងអាចនិយាយចេញមកបានក្នុងពេលនេះ។ ភ្នែកនាងសម្លឹងបុរសចំពោះមុខយ៉ាងមុតហាក់បញ្ជាក់ថា គ្រប់យ៉ាងដែលគេបានគិតជារឿងជូរចត់ ជារឿងប្រមាថកាត់ទានថែមទាំងគ្មានការពិតសូម្បីត្រឹមមួយភាគណា។

ពិសិដ្ឋមិនដែលទុកនាងជាការដោះដូរទេ! ចំណែកនាង ដែលហ៊ានក្រាបផ្ទឹមទទួលយកគេមកជាស្វាមីទាំងដែលគេគ្មានសមត្ថភាពធ្វើជាប្ដីបានក្ដី ក៏នាងមិនដែលគិតថាជាតិនេះនឹងគេចវេះចោលការថែទាំមើលគ្នាលុះចាស់រៀងខ្លួននោះដែរ។

គីម៉ាល់ត្រូវច្រានមិនរង្កើ ថែមទាំងរុលចុលមកធ្វើឱ្យនាងទាល់ច្រកច្រានគេជាលើកទីពីរ។ ជាមួយកំហឹង នារីនេះស្រែកបន្ថែម៖

«មនុស្សកាមតណ្ហាបាំងមុខ!»

គីម៉ាល់ស្មើមុខ ជាមួយពាក្យថាស្ដីកប់ៗ សំខាន់ប៉ះចំចំណុចខ្សោយពិតរបស់ខ្លួន។ នាងសម្លក់គេមុនបែរដើរចេញ តែគីម៉ាល់រហ័សជាង ដៃគេមួយច្បាមលើខ្នងនាង និងដៃម្ខាងទៀតចាប់ចង្កេះ បង្ខិលហាន់ដា ឱ្យបែរមកវិញ។

រាងកាយស្រឡូនតូច ដែលគេធ្លាប់កាន់កាប់កាលពីក្នុងកំណាត់វាំងននលើកូនទូកកាលល្ងាចម្សិលសារជាថ្មីស្ថិតក្នុងប្រអប់ទ្រូងនាយ។

ហាន់ដាឆ្អែតចិត្តណាស់ ស្របពេលសម្រិបជើងមនុស្សនៅខាងក្រៅលាន់ប្រះប្រស់លើស្លឹកឈើក្រៀមបង្ខំនាងឱ្យពោលព្រមានជាបន្ទាន់៖

«គីម៉ាល់ ប្អូនខ្ញុំមកឃើញឥឡូវហើយ លែងខ្ញុំភ្លាម!»

បុរសបង្ហាញភាពឈឺចាប់តាមរយៈបបូរមាត់ដែលនៅកៀកកិតក្បែរច្រមុះស្រីបង្គើយ។ គេវាចាខ្សឹបៗផ្ទាញ់ផ្ទាល់នាង៖

«កុំថាប្អូន You! ទោះម្ដាយ You ឬពួកអាប៉ូលិសហែហមរបស់ You អ៊ុំ! ថែមជាមួយពួកដុកទ័រអត់បានការអស់នោះមកតម្រៀបជួរឈរនៅហ្នឹងទៀត ក៏មនុស្សកាមតណ្ហាបាំងមុខម្នាក់នេះទទួលយកសេវាផ្សំដំណេកបានដែរអូន! បានគ្រប់ពេលអូន!»

នាងហួសចិត្ត នាងភាន់ភាំងចិត្ត នាងគាំងមិនដឹងត្រូវនិយាយថាម៉េចតបនឹងបុរសនេះ ជាមួយឫក ពាសម្តីសំដៅក្តៅគគុក១៨០ដឺក្រេរបស់គេ។

ទ្រូងស្រីលោតចុះឡើងតាមចង្វាក់ស្នូរដង្ហើមចេញពីកអាវស្តួចតូច ផ្ចិតផ្ចង់សម្រស់នាងក្នុងភាពពេញលេញនៃមនុស្សស្រីសែនទាក់ទាញមួយកម្រិតហើយមួយកម្រិតទៀត។

នៅមិននៅយើងនិយាយបញ្ឈឺគេឱ្យលេចចេញចរិតពាលមកទៀតទាល់តែបាន!

ដោះស្រាយយ៉ាងណាទៅនាង?

គេមិនដែលយកកំហឹងទៅទប់ជាមួយកំហល់បានទេនាងហាន់ដា!

ស្រីបន្ទោសខ្លួនឯងយ៉ាងអាថ៌កំបាំងក្នុងចិត្តរួចធ្មេចភ្នែកសងខាងយឺតៗខឹងមាត់ប៉ប៉េះរបស់ខ្លួនឯង។ ទោះនិវត្តមានស្មារតីមិនគ្រប់ តែរូបភាពបែបនេះមិនមែនជារឿងល្អនៅចំពោះមុខគេដាច់ខាត។

គឺម៉ាល់ គេហាមាត់រង់ចាំស្តាប់ពាក្យដោះសារ ។ កែវភ្នែកទាំងសងនៃប្រុសម្នាក់នេះ សម្លឹងរកភាពតតាំងគ្នាក្នុងប្រសីភ្នែកនាង តែមកឃើញខាងស្រីបិទភ្នែក ជិតឈឹង។

«ខ្ញុំសុំទោស!»

ទោសៈបុរសថមថយ។ គេចង់បន្ទូរដៃតែបបូរមាត់និងបេះដូង ច្រមុះនៅមិនព្រមស្តាប់បញ្ជា។ នាសាប្រុសថ្លៃ រេមកស្រូបស្រង់ក្លិនបុស្បាដែលកំពុងតែក្តៅរោលរាលដោយភាពរិប្បយោគ។

ក្បែរត្រចៀកនាង រហូតស្រីទទួលអារម្មណ៍ប៉ះបបូរមាត់គេ មិនដឹងគេចង់ខ្សឹបៗថាម៉េចទេ នាងឃាត់មុនៈ

«កុំធ្វើអ៊ីចឹងនៅនឹងមុខប្អូនខ្ញុំបានទេ!»

«ឱ្យជំពាក់បាន! តែមិនយូរទេ  ហាន់ដា!»

នាងនៅស្ងៀមមិនរើ មិនឆ្លើយ គឺទ្រាំឱ្យឈុតឆាកឆាប់ចប់ទៅ។ រាងកាយសព្វគ្រប់កន្លែងក្នុងរង្វង់ក្រសោបរបស់នាយ រញ៊ីរញ៉រដូចទើបនឹងប៉ះជាមួយបបូរមាត់មនុស្សប្រុសជាលើកដំបូង។ បុរសនេះសួរខ្លួនឯងជាសម្ងាត់ក្នុងបេះដូង។ ហេតុអ្វីនាងមើលទៅដូចមិនធ្លាប់ឆ្លងកាត់ឆាកស្នេហា? ឫកពាដូចមនុស្សមិនធ្លាប់សូម្បីប៉ះពាល់ជាមួយភេទផ្ទុយ? រាល់ពេលនៅកៀកគ្នាម្តងៗនាងញាប់ញ័រដល់ម្លឹង?

«ហាន់ដា នាងមិនឃោរឃៅដល់ថ្នាក់រៀបការហើយមិនឱ្យពិសិដ្ឋរួមរស់ជាប្តីប្រពន្ធពិតប្រាកដទេដឹង?»

គេលែងដៃសន្សឹមៗដរាបណានឹកឃើញដល់ប្អូនប្រុស។ ស្រស់ស្រីបើកភ្នែកមកវិញហើយប៉ុន្តែនាងងាកមុខសម្លឹងទៅទិសដៅទ្វារ ទាំងស្លេឹតស្លក់ភ័យព្រួយ។ គីម៉ាល់ប្រើហត្ថទាំងសងទាញរៀបចំសំពត់អាវខ្ចីខ្ចុករបស់នាង មាត់គេនិយាយខ្សឹបខ្សៀវបន្ថែម៖

«៧០ម៉ឺនហ្នឹង បើថាគ្មានសងទេ អាចរើសជម្រើសផ្សេង! ទីមួយ ត្រឡប់ទៅផ្ទះនៅភ្នំពេញភ្លាមៗថៃទាំផ្ទះ ធ្វើជាប្រពន្ធល្អកាន់ទុក្ខគោរពប្ដី ថៃទាំមរតក ការងារជំនួញខាងប្ដី អស់មួយជីវិត! ទីពីរ ផ្សំដំណេកបន្តជាមួយបងថ្លៃ បន្តកុងត្រាចាស់!»

នាងងាកមុខចេញទាំងក្ដាញ់ខឹង។ តែស្រីមិនឆ្លើយឆ្លងទេ។ មួយណាក៏នាងមិនធ្វើ នេះជាចម្លើយភ្លាមៗចេញពីបេះដូងគ្រាន់តែនាងមិនហាឱ្យសាមីម្ចាស់បំណុលឮ។

«បងនីដាខ្ញុំថតអំពិលអំពែក!»

និវត្តឡើងមកដល់។ ប្អូននាងអាយុ១៩ឆ្នាំហើយគេជាមានសមត្ថភាពខួរក្បាលស្មើក្មេងអាយុ៥ឆ្នាំ។ ជំងឺនេះគ្មានថ្ងៃមើលជាទេ តែក៏ល្អដែលគេមិនអាចសម្គាល់ដឹងទុក្ខវេទនាក្នុងទ្រូងបងស្រី។

នាងញញឹមនិយាយមួយៗ៖

«តស់ ទៅផ្ទះវិញនិវត្តយប់ហើយ!»

នាងបេះកាមេរ៉ាពីដៃប្រុសក្មេងដាក់ថ្មមៗលើសាឡុងឈើទាំងចិត្តប្រេះរហែក ពេលក្រឡេកឃើញសំណុំឯកសារនានាសល់ពីអតីតស្វាមី។

«កាមេរ៉ាជារបស់និវត្តរូបថតទាំងអស់ក្នុងនេះជាស្នាដៃរបស់គេ! យកតាមខ្លួនទៅ!»

បុរសនិយាយទៅរកក្មេងប្រុសជំទង់ ខណៈនិវត្តសប្បាយអរស្ទុះទៅរកឧបករណ៍តែនាងរារាំង៖

«កុំចង់បានរបស់អ្នកដទៃ វាគ្រោះថ្នាក់! គ្មានអីដែលបានមកទទេមិនគិតថ្លៃទេ! តោះទៅជាមួយបង!»

នាងឆ្លៀតសម្លក់គេចុងភ្នែកដោយភាពឆ្អែតចិត្តមុនពេលចាកចេញ។

«ជម្រើសទាំងពីរ ពេញចិត្តមួយណាឆាប់ឆ្លើយប្រាប់ផង!»

គីម៉ាល់ច្រត់ចង្កេះនិយាយឌឺដងពីក្រោយដំណើរនាង។

# សំណាញ់កលល្បិច

«ពីរនាក់ហ្នឹង មើលយ៉ាងណា ក៏នៅតែដូចជាស្រមោចនិងស្ករ»

បុរសចំណាស់ឈ្មោះឃឹមនិយាយពីក្រោយខ្នងតិចៗ ធ្វើឱ្យលោកជំទាវសក់ខ្លី ដាក់ទូរសព្ទដៃចុះលែងមើលឃ្លីបវីដេអូ ដែលទើបនឹងត្រូវបានអ្នកស៊ើបឯកជនផ្ញើមក។

ក្រៅភាពរឹករវរនិងពន្លឺភ្នែកដ៏ឃោរឃៅ នារីភាវ័យ២៦ឆ្នាំ ធ្លាប់ជាប្រពន្ធចុងនៃគ្រួសារម្ចាស់សណ្ឋាគារកម្រិតកំពូលនៅក្នុងព្រះរាជាណាចក្រទេសចរប្រវត្តិសាស្ត្រដ៏អស្ចារ្យមួយនេះ មិនមែនអរសប្បាយជាមួយវីដេអូនៃពិធីដឹកដៃរបស់គីម៉ាល់ ជាមួយហាន់ដានៅវាលត្រែងយប់មិញទេ។

ដល់ពូខ្លួន មកហាមាត់ធៀបពួកគេទៅនឹងស្រមោចជាមួយស្ករទៀត នាងរឹតតែផុសកម្តៅក្នុងទ្រូង។

ការរៀបអាពាហ៍ពិពាហ៍ដ៏ឆ្កួតលីលាកាលពី៨ឆ្នាំមុន មិនមែនជាបេះដូងនាងពិតៗទេក្រៅពីមរតកទ្រព្យនិងជីវភាពប្រណីតសុខដុមចេញ នាងតែងលាក់ទុកចិត្តសង្ឃឹមក្នុងការបានទទួលស្នេហាមួយ ពីកូនប្រុសច្បងរបស់ប្តីចំណាស់ខ្លួន ពិស័កហៅគីម៉ាល់។

«លើកនេះយើងមកស្ទឹងត្រែងមិនមែនមកមើលរឿងរ៉ូមែនទិកទេ! កុំភ្លេចបេសកកម្មធំរបស់ក្រុមយើង!»

នាងនិយាយតិចៗទាំងទោមនស្សនិងលើកកែវស្រាខ្មៅក្រឹបមកឱបក្បែរកំភួនដៃ។

នៅក្នុងអាវសូត្រក្រហមឆៅ និងស្អាតប្រណីតអ្នកមេម៉ាយនេះតុបតែងខ្លួនបំព្រងស៊ិចស៊ីហាក់បីដូចជាកំពុងរង់ចាំទេវបុត្រណាម្នាក់មកបង្ហាញខ្លួនក្នុងទិវារាត្រីរបស់នាង។ បេះដូងដែលស្ថិតនៅឯកាកំព្រាក្រោមស្រាមួយកែវនេះហាក់មានបង្កប់នូវចិត្តប្រតិព័ទ្ធ លើសលប់លើប្រុសស្អាតម្នាក់នោះនៅឡើយ មិនមែនពូឃឹមមិនដឹងទេ។ ដូច្នេះហើយ ជាជាងឆ្លើយតបសំណួរនាង គាត់បែរជាឆ្លៀតដាស់តឿន៖

«សង្ឃឹមថាក្មួយស្រីដ៏ខ្ពង់ខ្ពស់និងស្រស់ស្អាតរបស់ខ្ញុំ ក៏ចងចាំពីបេសកកម្មរាប់លានរបស់យើងដូចគ្នា!»

នាងនៅដៀងភ្នែកស្តាប់ ស្របពេលឪពុកមាដើរមួយៗមកក្បែរនិងនិយាយបន្ថែមទៀត៖

«ដំបូងឡើយ គិតថាគ្រប់យ៉ាងនឹងឆាប់ចប់នៅលើទន្លេមេគង្គនេះ! អ្នកស្នងមរតកគ្មានថ្ងៃបានវិលទៅផ្ទះធំនៅភ្នំពេញវិញទេ រឹតតែមិនអាចទៅគ្រប់គ្រងសណ្ឋាគារបានផង! តែមិនទាន់អី ស្រាប់តែតែតួប្រុសបង្ហាញមុខ! សង្ឃឹមថាមិនមានអ្នករារែកក្នុងការបញ្ចប់ឈុតឆាកតួប្រុសកណ្តាលរឿងទេ!!»

នារីអភិជនធ្មេចភ្នែកខាំមាត់ជូរចត់។ បបូរមាត់ក្រហមក្រមៅរបស់នាង បានរំឭកឡើងវិញនូវអនុស្សាវរីយ៍មួយដែលជាការសម្រេចចិត្តធំបង្អស់ក្នុងជីវិតរបស់ខ្លួនកាលពីជាង៨ឆ្នាំមុន។

មុនពេលពិធីមង្គលការមួយសម្រាប់ផ្តាប់ចិត្តម្តាយនិងពូម្នាក់នេះកើតមានឡើង នាងបានលះបង់ចោលគេ គឺសង្សារស្រស់សង្ហាដែលជាកូនប្រុសច្បងនៃបុរសវ័យជរាដែលខ្លួនត្រូវរៀបការជាមួយ។

នារីភាដឹងថាគីម៉ាល់ស្រលាញ់នាងកម្រិតណា តែគេត្រឹមជាកូនប្រុសម្នាក់ ដើរហើរពាសវាលគ្មានអាជីព គ្មានទ្រព្យកម្មសិទ្ធិ ។ ប្រសិននឹងរង់ចាំផ្សងវាសនាជាមួយគេ មិនដឹងពេលវេលាណានឹងអាលទទួលបានងារជាលោកជំទាវវ័យក្មេងជាងគេ ក្នុងសង្គមជាន់ខ្ពស់នៅភ្នំពេញ និងមានជីវិតមួយប្រៀបបាននឹងម្ចាស់ក្សត្រីទល់សព្វថ្ងៃនោះឡើយ។

«កាល៨ឆ្នាំមុន ខ្ញុំតាមពូនិងម៉ែ ឱ្យគ្រប់គ្នាបានធូរស្បើយពីជីវិតដែលរុំព័ទ្ធដោយបំណុលល្បែងហើយទៅការជាមួយមនុស្សចាស់ស្មើឪពុក! ពេលនេះ ជីវិតនរកបានបញ្ចប់ ខ្ញុំកំពុងធ្វើអ្វីមួយដែលត្រឹមត្រូវឡើងវិញសម្រាប់ខ្លួនឯង! អ្នកណារារាំងខ្ញុំ អ្នកនោះនឹងលិចចូលក្នុងទន្លេនេះ!»

ពូឃឹមដឹងថាកំហុសដ៏ធំរបស់គាត់និងបងស្រី គឺបានបង្រៀននារីភាតូចតន់ស្លូតបូត ឱ្យលោភលន់និងកាចសាហាវ។ មេរៀនចិត្តដាច់និងអសីលធម៌ដែល មនុស្សស្រីវ័យក្មេងម្នាក់ហ៊ានធ្វើគ្រប់យ៉ាងសូម្បីតែរឿងក្បត់ផិត ដើម្បីលុយទៅហើយ ពេលនេះទៀតប្តីនាងស្លាប់បាត់ ថែមត្រូវស្រងាកចិត្តនិងមរតកដែលមិនបានមួយចំណិតណាស់ជាដុំកំភួនផង នាងកាន់តែវិលវល់ ឪប្រេស និងបានក្លាយជាមនុស្សមិនខ្លាចសូម្បីតែការធ្វើអំពើជាសត្វតិរច្ឆាន។

ពូឃឹមដឹងថា នារីភាម្នាក់ដែលមុននេះ ចង់បានត្រឹមតែអំណាចនិងលុយកាក់មាសប្រាក់ ពេលនេះបានបន្ថែមគោលដៅមួយទៀតទៅក្នុងកែវស្រាក្រម៉ៅរបស់នាង ក៏ជាគោលដៅដែលគាត់ពិបាករកមកឱ្យនាងបាន នោះគឺ«ប្រុសស្អាត»។

«ជំទាវកុំញ៉ាំស្រាច្រើនពេក! វាមិនល្អទេ»

សំឡេងតូចៗរបស់ពូខ្លួនមិនបានឱ្យនាងថមថយភាពមានៈ ឬព្រមយល់ចិត្តឈឺឆ្អាលរបស់គាត់ទេ នាងនិយាយទាំងឪដងតបវិញ៖

«កាលពី៨ឆ្នាំមុនក្រែងពូនិងម៉ែបានបង្រៀនខ្ញុំឱ្យធ្វើរឿងមិនល្អច្រើនមកហើយនោះអី? »

នាងងាកមកក្រោយ ទាំងកែវភ្នែកស្រស់បំព្រងដោយក្ងោកបង្អួតកន្ទុយ សម្លឹងពូខ្លួនមុនពេលចរចាបន្ថែម៖

«ត្រឹមស្រាប៉ុណ្ណឹងៗទុកថាមិនល្អអីទៀត?!»

នាងលើកញញឹមបង្ហាញស្នាមខួចសងខាងថ្ពាល់ មុនពេលលើកដាច់ក្អឹកៗ នឹងចាប់ផ្តើមសើចក្អាកក្អាយរីករាយ។

ពូឃឹមដកដង្ហើមធំ។

«ពូដកដង្ហើមធំ? ឃើញក្មួយផឹក ត្រឹមប៉ុណ្ណឹងៗ ចេះដង្ហើមធំទៅហើយ ពូឃឹម? សួរដូចឆោត ដែលស្រមៃអត់ថា ក្មេងស្រីម្នាក់អាយុ១៩ឆ្នាំ មានសង្សារសង្ហាដូចព្រះអង្គម្ចាស់ នៅមិននៅ ត្រូវទៅឡើងគ្រែជាមួយតាកញ្ចាស់ អាយុក្បែរ៧០ឆ្នាំម្នាក់ អ្ហះ? ពូនិងម្តាយខ្ញុំ ដែលដឹងថា ខ្ញុំនេះ នាងនារីភាម្នាក់នេះ ធ្លាប់ចង់ស្លាប់ប៉ុន្មានដងដែរទេ? អ្ហះ?!»

«វាជាកំហុសរបស់ពូ! កុំថាអីឱ្យបងស្រី! គាត់ស្លាប់ហើយ! តាមពិតគាត់មិនដែលចង់ឱ្យកូនស្រីឈឺចាប់ទេ!»

នារីភាងាកមុខចេញ។ បុរសបង្ហាញភាពឈឺចាប់ក្នុងចិត្តតាមរយៈការអង្គុយចុះលើសាឡុងភឹង។ មាត់និយាយបន្ត៖

« មកពីគាត់ស្រលាញ់ប្អូនពេក គាត់ខ្លាចពូនេះត្រូវជាប់គុក! ខ្លាចត្រូវគេវាយពូ! ពួកនៅក្នុងគុក សុទ្ធជាសត្រូវចាស់ បើពូចូលទៅមែន ពូស្លាប់យូរហើយ !»

ស្នាមញញឹមដែលរាលដាលពាសពេញផ្ទៃមុខនាង ធ្វើឱ្យខ្ញុំមានអារម្មណ៍បុរសចំណាស់រឹតតែឈឺចាប់ឡើង។

«វាជាកំហុសពូទាំងអស់»

គាត់វាចាផ្ទួន។ នាងងក់ក្បាលទទួល ហើយវាចាតប ទាំងដៃចាក់ស្រាបន្ថែមរូវៗ៖

«អ៊ីចឹងពូយកគេនោះមកឱ្យខ្ញុំឱ្យបាន លាងទោសរបស់ពូ!»

ពូឃឹមនៅស្ងៀម។

គាត់ដឹងថាក្មួយស្រវឹងទ្រេតហើយ ។ បន្ថែមលើបេះដូងដែលស្រវឹងស្នេហ៍ព្រោះកំពុងរើបរើ រងើកភ្លើងមនោសញ្ចេតនាចាស់ ផ្លូវចិត្តក្មួយម្នាក់នេះ សឹងតែទន់ខ្សោយរាយមាយខ្លាំង ប្រសិនបន្តនិយាយគ្នាបន្ថែមទៀតក៏សឹងមិនបានជួយស្រង់អ្វីឡើងវិញទេ ។

តែគាត់ដឹងថា សភាពខាងប្រុសគឺលែងមានស្រមោលនាងជាយូរណាស់មកហើយ គ្រាន់តែមិនអាចនិយាយប្រាប់។

យឹមក្រោកឡើងមកបម្រុងចាកចេញតែដៃរបស់ក្មួយ លោមកព័ទ្ធជុំវិញស្មារបស់គាត់។ នាងនិយាយដូចពាក់កណ្ដាលដេកលក់៖

«ណា៎! ទៅយកគីម៉ាល់មកឱ្យខ្ញុំ! ខ្ញុំដឹងពូមានវិធី! ពូធ្វើបាន! យកគេមក ឱ្យគេលួងជីវិតចុងក្រោយរបស់ខ្ញុំ ខ្ញុំលើកទោសឱ្យពូ! ទុកថាយើងរួចគ្នា!»

សភាពរបស់នាង មើលទៅគួរអោយខ្លាចច្រើនជាងអាណិត។ ពូយឹមនេះឆ្លងកាត់អាក្រក់ល្អ សខ្មៅច្រើនមិនអស់មកហើយ ពេលនេះម៉ោងនេះកាត់មើលដឹងថា នារីភា មិនមែនមានមនោសញ្ចេតនាចាស់ទេ តែនាងចង់ឈ្នះព្រហ្មលិខិត ចង់ឈ្នះហាន់ដា ចង់ឈ្នះភ័ព្វព្រេងវាសនានិងឈ្នះមនុស្សគ្រប់គ្នា។

ឯងស្រវឹងហើយដេកទៅ!

ពូប្រាប់ហើយ បេះដៃក្មួយចេញ។ មកដល់ក្រៅបន្ទប់ ហ្វូងដែលតាមបម្រើដូរបាយកំពុងរង់ចាំរហង់។ ពូយឹម ធ្វើចលនាដៃឱ្យសញ្ញាពួកគេ ឱ្យចុះក្រោមសិនសឹមនិយាយគ្នា។

ម្នាក់ឈ្មោះអិន ក្នុងចំណោមនោះឱនមកខ្សឹបដាក់បុរសជាមេកោយ៖

«តាមមើលទៅ គីម៉ាល់នោះមិនឆេវឆាវធ្វើបាបហាន់ដាជំនួសយើងទេ! ចង់ខ្ចីដៃគេសម្លាប់មនុស្សក្រែងតែពន្យារពេលអត់អំពើទេ ល្បង!»

យឹមក្រឡេកមើលមុខអិន ដែលជាសេនាដៃស្ដាំបានដើរតាមកម្សត់កម្រជាមួយគ្នាច្រើនឆ្នាំមកហើយ។ បុរសចំណាស់ក៏ទាយដឹងដែរថា ជាមួយជម្រើសរបស់គីម៉ាល់ ហាន់ដាដឹងតែយល់ ព្រមវិលទៅភ្នំពេញ ថែទាំគ្រួសារ គ្រប់គ្រងអាជីវកម្មគេមិនខាន។ នាងមិនអាចរើប្រឆាំងទេ លើកលែងតែនាងយកជម្រើសទីពីរដែលគេងកំដរគេជំនួសប្ដីដែលស្លាប់។

«នេះជាចេតនាល្អរបស់គីម៉ាល់ក្នុងការទុកកេរមរតកទាំងអស់ឱ្យទៅហាន់ដាគ្រប់គ្រង!»

យឹមរអ៊ូតិចៗ អិនងក់ក្បាលយល់ស្រប។

យឹមដៀងភ្នែកសម្លឹងទៅបន្ទប់ក្មួយស្រី។ បុរសនេះពិបាកចិត្តព្រោះវិញ្ញាសាថ្មីដែលនាងទើបតែទាមទារឱ្យខ្លួនដោះស្រាយមុននេះ។ គិតចុះឡើងបានបន្តិច អិនឱ្យយោបល់មកភ្លាម៖

«បងយឹម! ខ្ញុំគិតថា អ្វីដែលយើងគួរធ្វើគឺពន្យារពេលឱ្យស្រីម្នាក់ហ្នឹងនៅណេះសិន!!»

យឹមគិតយ៉ាងរហ័សហើយងាកសម្លឹងមុខកូនចៅ។ គាត់ងក់ក្បាលយឺតៗយល់ស្រប....